***កម្ពុជា***

ផលិតផលក្នុងស្រុកសរុប (GDP) ពិតប្រាកដរបស់កម្ពុជា បានកើនឡើងត្រឹម ១៣,៤ភាគរយ ហួសពីការស្មាន នៅក្នុងឆ្នាំ ២០០៥[១] ។ កំណើនដែលកើនឡើងខ្ពស់នេះ គឺកើនឡើងដោយសារការនាំចេញសំលៀកបំពាក់ដ៏ច្រើន វិស័យទេសចរណ៍ កំណើនវិនិយោគទុនផ្ទាល់ពីបរទេស ការសាងសង់ដែលកំពុងបន្ត និងដំណាំកសិកម្ម ។ វិស័យកសិកម្មនៅតែជាវិស័យដ៏សំខាន់មួយចំពោះសេដ្ឋកិច្ច ស្មើនឹង ៣៨ ភាគរយនៃកំណើន GDP និងស្មើប្រមាណ ៦០ភាគរយ នៃការងារសរុប ក្នុងឆ្នាំ ២០០៥ ។ គេរំពឹងថា កំណើនក្នុងឆ្នាំ ២០០៦ នឹងមានចំនួនប្រមាណ ៨,៩ភាគរយ ដោយសារតែមានការយឺតយ៉ាវក្នុងការពង្រីកការងារសំណង់ និងកសិកម្ម ។ អតិផរណាថ្លៃអ្នកប្រើប្រាស់ ត្រូវបានគេប៉ាន់ប្រមាណថា នឹងធ្លាក់ចុះមកនៅប្រហែល ៥ភាគរយ ក្នុងឆ្នាំ ២០០៦ ថយចុះពី ៦,៧ភាគរយនៅក្នុងឆ្នាំ ២០០៥ ។ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដ៏ល្អមួយ បានជួយគាំទ្រជ័យជំនះក្នុងឆ្នាំ ២០០៦ ។ ក៏ប៉ុន្តែ មូលដ្ឋានកំណើនដ៏តិចតួចរបស់កម្ពុជា នៅតែជាបញ្ហាគួរអោយព្រួយបារម្ភ ។ ការងារបច្ចុប្បន្ន និងការងារដែលកំពុងដំណើរការ (រួមទាំង យុទ្ធសាស្ត្រនាំចេញថ្នាក់ជាតិ ២០០៧-២០១០ ក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ២០០៥-២០១០ និងដំណាក់កាលទីពីរនៃក្របខ័ណ្ឌរួម (IF) សំរាប់ពាណិជ្ជកម្ម) មានទិសដៅដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ។

វិស័យក្រៅប្រទេសរក្សាបាននូវកំលាំងកំណើនរបស់ខ្លួន កើនឡើង ១១ភាគរយ ក្នុងឆ្នាំ ២០០៥ លើការនាំចេញសំលៀកបំពាក់ ។ ឧស្សាហកម្មសំលៀកបំពាក់ ទទួលបានអត្ថប្រយោជន៍ពីវិធានការទប់ស្កាត់ការនាំចូលសំលៀកបំពាក់របស់ចិន ដែលកំណត់ដោយសហរដ្ឋអាមេរិក និងសហភាពអឺរុប នៅពាក់កណ្តាលឆ្នាំ ២០០៥ ។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគនិងពាណិជ្ជកម្ម (TIFA) រវាងកម្ពុជា និងសហរដ្ឋអាមេរិក នៅខែកក្កដា ឆ្នាំ ២០០៦ ត្រូវគេរំពឹងថា នឹងជំរុញបន្ថែមអោយមានពាណិជ្ជកម្មទ្វេភាគី ។ វិស័យក្រៅប្រទេស ក៏បានមើលឃើញផងដែរថា មានការកើនឡើង ៤៤ភាគរយ លើផ្នែកទេសចរណ៍ និងច្រើនជាងទ្វេដងនៃ FDI ។ វិស័យក្រៅប្រទេសនៅតែរឹងមាំ ដែលការនាំចេញត្រូវបានគេរំពឹងថានឹងកើនឡើងត្រឹម ១៥ភាគរយ នៅឆ្នាំ ២០០៦ និង FDI បន្តកើនឡើង ។ ទោះបីជាគេប៉ាន់ប្រមាណថា កំណើនការនាំចេញខ្លាំងក៏ដោយ ក៏ឱនភាពពាណិជ្ជកម្ម ត្រូវបានគេព្យាករណ៍ថានឹងកើនឡើងដល់ ២០ភាគរយ នៃ GDP ក្នុងឆ្នាំ ២០០៦ កើនពី១៦ភាគរយ ក្នុងឆ្នាំ ២០០៥ ដោយសារតែកំណើនការនាំចូលលឿនជាង ។ ប្រភពធនបរទេសសរុប ត្រូវបានគេប៉ាន់ប្រមាណថា នឹងកើនឡើងដល់ ១,១ ពាន់លានដុល្លារអាមេរិក (ពី ០,៩ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៥) និងអត្រាប្តូរប្រាក់ ត្រូវបានគេប៉ាន់ប្រមាណថា នឹងថយចុះបន្តិចបន្តួច (០,៨ភាគរយ) ធៀបនឹងដុល្លារអាមេរិក ។

---

[១] តួលេខកំណើនផ្លូវការ មិនដូចទាំងស្រុងទៅនឹងតួលេខក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះទេ ពីព្រោះវាក៏បានឆ្លុះបញ្ចាំងផងដែរអំពីការផ្លាស់ប្តូរមួយចំនួននៃវិធីសាស្ត្រគណនីជាតិ រួមទាំងវិធីសាស្ត្រកែប្រែរបៀបចងក្រងនិងគ្រប់គ្រងស្ថិតិ ។ តួលេខប្រហាក់ប្រហែលមួយ បង្ហាញថាកំណើនឆ្នាំ ២០០៥ មានប្រហែល ៩,៨ភាគរយ ។

សកម្មភាពសេដ្ឋកិច្ច មានការកែលំអបន្តិចបន្តួច នៅក្នុងឆ្នាំ ២០០៥ ដែលប្រាក់ចំណូលសរុបកើនឡើងបន្តិចបន្តួចពី ១០,៤ ភាគរយ នៃ GDP ក្នុងឆ្នាំ ២០០៤ មក ១០,៥ ភាគរយក្នុងឆ្នាំ ២០០៥។ គេរំពឹងថា ប្រាក់ចំណូល នឹងកើនឡើងដល់ ១២ ភាគរយ នៃ GDP ក្នុងឆ្នាំ ២០០៦ ដោយសារកំណើនលើការប្រមូលពន្ធក្នុងស្រុកនិងក្រៅស្រុក។ ចំណែកឯប្រាក់ចំណូលមិនមែនជាប្រាក់ពន្ធ ត្រូវគេរំពឹងថា នឹងស្ថិតនៅថេរ ជាចំណែកមួយនៃ ផ.ស.ស។ ការចំណាយ បានកើនឡើងបន្តិចបន្តួចដល់ ១៣,៨ ភាគរយ នៃ GDP ក្នុងឆ្នាំ ២០០៥ ក៏ប៉ុន្តែ ត្រូវគេរំពឹងថា នឹងកើនឡើងដល់ ១៤.៤ ភាគរយ ក្នុងឆ្នាំ ២០០៦ ដែលឆ្លុះបញ្ចាំងអោយឃើញពីកំណើនលើចំណាយបច្ចុប្បន្ន។ ផលប៉ះពាល់នៃវិធានការចំណូលនិងចំណាយ ត្រូវគេ រំពឹងថា នឹងកាត់បន្ថយឱនភាពទូទៅ (មិនរាប់បញ្ចូលជំនួយឥតសំណង) ពី -៣,៤ មក-២,៦ ភាគរយ នៃផ.ស.ស ក្នុងឆ្នាំ ២០០៦ ជាមួយនឹងឱនភាពដែលរាប់បញ្ចូលទាំងជំនួយឥតសំណងធ្លាក់ចុះមកដល់ ០,៩ភាគរយ ក្នុងឆ្នាំ ២០០៦។

កំណើនលើរូបិយប័ណ្ណទូទៅ ត្រូវគេរំពឹងថា នឹងកើនឡើងត្រឹមប្រមាណ ២៧ភាគរយក្នុងឆ្នាំ ២០០៦ ខ្ពស់ជាងឆ្នាំ ២០០៥ បន្តិចបន្តួច។ ឥណទានវិស័យឯកជន ត្រូវបានគេរំពឹងថានឹងបន្តកើនឡើង នៅក្នុងឆ្នាំ ២០០៦ ក្នុងអត្រាកំណើនប្រហែល ៣៥ភាគរយ។ ក៏ប៉ុន្តែ អត្រាការប្រាក់ពាណិជ្ជកម្ម នៅតែមានកំរិតខ្ពស់ ប្រហែល ១៥ ភាគរយ ក្នុងមួយឆ្នាំ។

លើរបៀបវារៈកំណែទំរង់រចនាសម្ព័ន្ធ កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ដែលប្រកាសដោយលោកនាយករដ្ឋមន្ត្រី នៅក្នុងខែធ្នូ ឆ្នាំ ២០០៤ កំពុងតែចាប់ផ្តើមអោយផ្លែផ្កា។ បរិមាណប្រាក់ចំណូលគយ ដែលប្រមូលបានតាមរយៈប្រព័ន្ធធនាគារ បានកើនឡើងពី សូន្យ ក្នុងឆ្នាំ ២០០៤ ដល់ ៣៦ភាគរយ ក្នុងឆ្នាំ ២០០៥ ហើយគ្រោងនឹងបង្កើនថែមទៀតក្នុងឆ្នាំ ២០០៦។ ៨៦ភាគរយនៃប្រាក់ចំណូលសរុបរបស់នាយកដ្ឋានពន្ធដា បច្ចុប្បន្ន ត្រូវបានប្រមូលតាមរយៈប្រព័ន្ធធនាគារ។ ការកើនឡើងនៃការទូទាត់របស់រតនាគារ ដល់អ្នកផ្គត់ផ្គង់ ត្រូវបានធ្វើឡើងដោយប្រើមូលប្បទានប័ត្រជំនួសអោយការទូទាត់ជាសាច់ប្រាក់សុទ្ធ។ ដំណើរការថវិកាប្រចាំឆ្នាំថ្មីមួយ ដែលបញ្ចូលកម្មវិធីបែងចែកថវិកា ត្រូវបានអនុម័ត។ សន្និធិប្រាក់ចំណាយដែលនៅសល់មិនទាន់ទូទាត់ ត្រូវបានកាត់បន្ថយត្រឹម ៤០ភាគរយ។ ដំណើរការលទ្ធកម្មត្រូវបានធ្វើអោយកាន់តែប្រសើរឡើង ត្រូវបានពង្រឹង និងធ្វើអោយកាន់តែមានលក្ខណៈប្រកួតប្រជែង។ រដ្ឋាភិបាល បានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅក្នុងក្រសួងពាក់ព័ន្ធជាច្រើន ហើយជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា កម្មវិធីសាកល្បងមួយ ត្រូវបានចាប់ផ្តើមឡើង ដើម្បីបើកប្រាក់ខែអោយមន្ត្រីរាជការតាមរយៈធនាគារពាណិជ្ជកម្ម ជំនួសអោយការបើកអោយជាសាច់ប្រាក់សុទ្ធ។ កម្មវិធីកំណែទំរង់ PFM ត្រូវបានគាំទ្រដោយម្ចាស់ជំនួយចំនួន ១១ (ចុងក្រោយគេ គឺធនាគារពិភពលោក) ដែលបានអនុម័តគំរោងជំនួយបច្ចេកទេសដែលមានទឹកប្រាក់ចំនួន ១៤លានដុល្លារអាមេរិក នៅក្នុងខែមិថុនា ឆ្នាំ ២០០៦។

កំណែទំរង់វិស័យហិរញ្ញវត្ថុ ដឹកនាំដោយផែនការវិស័យរយៈពេល ១០ឆ្នាំ ដែលត្រូវបានអនុម័តកាលពីឆ្នាំ ២០០១ ក៏មានការរីកចំរើនជឿនលឿនទៅមុខផងដែរ។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានមួយ ត្រូវបានបង្ហាញអោយដឹង ដោយផ្តល់

អោយធនាគារពាណិជ្ជកម្មនានានូវព័ត៌មានដែលទាក់ទងទៅនឹងឥណទានអំពីអតិថិជនសក្ដានុពល ដើម្បីកាត់បន្ថយការប្រព្រឹត្តិបទល្មើស និងការមិនសងបំណុល។ ការអភិវឌ្ឍប្រព័ន្ធទូទាត់ថ្នាក់ជាតិមួយ និងប្រព័ន្ធបច្ចេកវិជ្ជាព័ត៌មានដែលមានលក្ខណៈទូលំទូលាយមួយ សំរាប់មុខងារធនាគារ បានក្លាយជាបញ្ហាប្រឈមដ៏សំខាន់មួយសំរាប់វិស័យ។

បញ្ហាប្រឈមដ៏ធំបងមួយទៀតសំរាប់រដ្ឋាភិបាល គឺការអនុម័តច្បាប់មួយចំនួនដែលមានសារៈសំខាន់ចាំបាច់សំរាប់កិច្ចព្រមព្រៀង WTO រួមមានៈ ច្បាប់ធានាពាណិជ្ជកម្ម ច្បាប់ជួលក្នុងពាណិជ្ជកម្ម ច្បាប់ស្ដីអំពីការបោះពុម្ពនិងលក់ប័ណ្ណហិរញ្ញវត្ថុមិនមែនរដ្ឋាភិបាល ច្បាប់ក្ស័យធន និងច្បាប់ស្ដីអំពីការបង្កើតតុលាការពាណិជ្ជកម្ម និងច្បាប់ដទៃផ្សេងទៀត។